**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការពន្យារពេលនៃរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ របស់ រ.ទ.ស.ភ ដែលត្រូវផ្តល់ជូននិយ័តករមូលបត្រកម្ពុជា យ៉ាងយូរត្រឹមថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ នឹងត្រូវពន្យារពេលរហូតដល់ **ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១** ដោយសារ រ.ទ.ស.ភ ត្រូវធ្វើការផ្ទៀងផ្ទាត់គណនីចំណូល សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០ និងសម្រាប់ឆ្នាំ២០២០ ឱ្យស្របតាមស្តង់ដារគណនេយ្យ CIFRS 15 (ចំណូលពីកិច្ចសន្យាជាមួយអតិថិជន)។ ការយឺតយ៉ាវនេះ ធ្វើឱ្យការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មានការយឺតយ៉ាវផងដែរ។

ហេតុដូចនេះ របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ របស់ រ.ទ.ស.ភ ត្រូវពន្យារពេល ដោយសារការអវត្តមាននៃព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលជាផ្នែកសំខាន់នៃរបាយការណ៍ប្រចាំត្រីមាស។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទទួលជ្រាប។

ថ្ងៃច័ន្ទ ៤កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh